ក N°16/15→28/02/2015

# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៨-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១២៩ ស្តីពី ការតែងតាំងឯកឧត្តម **វ៉ាន សំអឿន** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ១៧៩៧

១៨-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៣០ ស្តីពី ការតែងតាំងឥស្សរជនចំនួន ០២ រូប ជាអនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ១៧៩៨

១៨-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៣១ ស្តីពី ការតែងតាំងឯកឧត្តម **ជា ថុន** ជាទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១៧៩៩

១៨-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៣២ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ចំនួន ០៣ រូប ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ១៨០០

១៨-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៣៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឧត្តមសេនីយ៍ឯក **ខួន ស្រេង** ១៨០២

១៨-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៣៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឯកឧត្តម **អ៊ុំ អ៊ួក** ១៨០៣

១៨-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៣៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ កងកម្លាំងប្រដាប់អាវុធ ចំនួន ៦៦ រូប ១៨០៤

១៨-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៣៦ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ចំនួន ៣៤ រូប ១៨០៧

១៩-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៣៧ ស្តីពី ការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ ចំពោះសពឯកឧត្តម **ពោន ពន្លឺ** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ១៨១០

១៩-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៣៨ ស្តីពី ការតែងតាំងឯកឧត្តមឧត្តមសេនីយ៍ឯក **លឹម ម៉ូវ** ជា ឧកញ៉ា ១៨១១

១៩-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៣៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ដល់ឯកឧត្តមឧត្តមសេនីយ៍ទោ **គឹម សុខុន** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១៨១២

១៩-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៤០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ដល់លោកឧត្តមសេនីយ៍ត្រី **ផាន់ សុផល** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១៨១៣

១៩-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៤១ ស្តីពី ការតែងតាំងឯកឧត្តម **ម៉ា ស៊ុនហួត** ជាអនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន ជំនួស ឯកឧត្តម **ស្លូត សំបូរ** ដែលបានទទួលមរណភាព ១៨១៤

១៩-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៤២ ស្តីពី ការតែងតាំងមន្ត្រីរាជការ នៃក្រសួងយុត្តិធម៌ ចំនួន ០២ រូប ១៨១៥

២០-០២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០២១៥/១៤៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី តាមលំដាប់ថ្នាក់ ចំពោះ កងទ័ពវៀតណាម ចំនួន ១០ រូប ១៨១៦

## II. រាជរដ្ឋាភិបាល

### អនុក្រឹត្យ

២៥-០២-២០១៥ -អនុក្រឹត្យលេខ ១៥ អនក្រ.បក ស្តីពី ការកែសម្រួលបៀវត្សមូលដ្ឋាន និងការបើកផ្តល់បៀវត្សដល់មន្ត្រីនគរបាលជាតិកម្ពុជា ១៨១៧

២៥-០២-២០១៥ -អនុក្រឹត្យលេខ ១៦ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១៨២១

២០-០២-២០១៥ -អនុក្រឹត្យលេខ ១៨៤ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ១៨២៣

២០-០២-២០១៥ -អនុក្រឹត្យលេខ ១៨៥ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពប្រធានផ្នែកក្នុងរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ១៨២៤

២០-០២-២០១៥ -អនុក្រឹត្យលេខ ១៨៦ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ១៨២៦

២១-០២-២០១៥ -អនុក្រឹត្យលេខ ១៨៧ អនក្រ.តត ស្តីពី ការតែងតាំងបន្ថែមសមាសភាពនៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ១៨២៩

២៣-០២-២០១៥ -អនុក្រឹត្យលេខ ១៨៨ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១៨៣១

២៣-០២-២០១៥ -អនុក្រឹត្យលេខ ១៨៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៨៣២

២៣-០២-២០១៥ -អនុក្រឹត្យលេខ ១៩០ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ១៨៣៥

២៣-០២-២០១៥ -អនុក្រឹត្យលេខ ១៩១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨៣៦

២៣-០២-២០១៥ -អនុក្រឹត្យលេខ ១៩២ អនក្រ.តត ស្តីពី ការផ្ទេរ និងសម្រួលភារកិច្ចមន្ត្រីរាជការ ១៨៣៧

២៣-០២-២០១៥ -អនុក្រឹត្យលេខ ១៩៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៨៣៨

២៤-០២-២០១៥ -អនុក្រឹត្យលេខ ១៩៤ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១៨៣៩

២៤-០២-២០១៥ -អនុក្រឹត្យលេខ ១៩៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៨៤១

២៤-០២-២០១៥ -អនុក្រឹត្យលេខ ១៩៦ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសសុវត្ថារា ១៨៤២

២៤-០២-២០១៥ -អនុក្រឹត្យលេខ ១៩៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨៤៣

២៤-០២-២០១៥ -អនុក្រឹត្យលេខ ១៩៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៨៤៥

២៤-០២-២០១៥ -អនុក្រឹត្យលេខ ១៩៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៨៤៧

២៤-០២-២០១៥ -អនុក្រឹត្យលេខ ២០០ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១៨៤៩

២៤-០២-២០១៥ -អនុក្រឹត្យលេខ ២០១ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ១៨៥០

២៤-០២-២០១៥ -អនុក្រឹត្យលេខ ២០២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៨៥១

២៤-០២-២០១៥ -អនុក្រឹត្យលេខ ២០៣ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីពន្ធនាគារ ១៨៥២

២៤-០២-២០១៥ -អនុក្រឹត្យលេខ ២០៤ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃ មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ១៨៥៤

*-អនុក្រឹត្យលេខ ២០៥ ដល់ ២០៩ អនក្រ.តត មិនទាន់បានទទួល*

២៤-០២-២០១៥ -អនុក្រឹត្យលេខ ២១០ អនក្រ.តត ស្តីពី ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូតជាន់ខ្ពស់ ១៨៥៦

២៤-០២-២០១៥ -អនុក្រឹត្យលេខ ២១១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៨៥៧

*-អនុក្រឹត្យលេខ ២១២ ដល់ ២១៥ អនក្រ.តត មិនទាន់បានទទួល*

២៤-០២-២០១៥ -អនុក្រឹត្យលេខ ២១៦ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ១៨៥៨

## III-ការងារបណ្ដាក្រសួង

## ទីស្ដីការក្រសួងពាណិជ្ជកម្ម

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៤០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អេសខេខេធី អេស៊ា ប៊ីហ្សូនេស ខូ អិលធីឌី** ១៨៥៩

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៤១ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការប្តូរទ្រង់ទ្រាយសហគ្រាស និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ព្រះខ័ន (ផ្លាហ្សា) ខូ អិលធីឌី** ១៨៦១

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៤២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **គីម យ៉ុង ស៊ា ត្រេឌីង** ១៨៦៣

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៤៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ពេញលក្ខណៈច្បាប់ របស់សាខាក្រុមហ៊ុន **ជីតចារ៉ឺន ខនស្ត្រាក់សិន** ១៨៦៥

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៤៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អឹមេហ្សុ ត្រេឌីង** ១៨៦៦

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៤៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឈុន ឌីង ព្រីនធីង ខូ អិលធីឌី** ១៨៦៨

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៥០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **តៃហ្វើ (ខេមបូឌា)** ១៨៧០

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៥១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **កោះរ៉ុង មើរីន** ១៨៧២

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៥២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ប៊ីលាន (ខេមបូឌា) នីតធីង ខមភេនី លីមីធីត** ១៨៧៤

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៥៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **វ៉ាន់ រ៉ាម៉ុន អ៊ីមផត អិចផត ខូ អិលធីឌី** ១៨៧៥

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៥៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អូស្ត្រាលាន រីសេស ផាតនើរ** ១៨៧៧

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៥៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហ្គ្លាន យ័ន មេធៀរៀល អ៊ិន ធើណេសិនណល ត្រេឌីង** ១៨៧៩

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៥៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ប្រៃវូខឡា ខូ អិលធីឌី** ១៨៨១

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៦៤ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ម៉ាយថេក ម៉ូប៊ីលីធី (ខេមបូឌា)** ១៨៨៣

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៦៥ ពណ.ចបព ស្ដីពី ការលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្ម របស់ក្រុមហ៊ុន **ភ្នំពេញ ហ្វអេវើ ហូថេល** ១៨៨៥

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៧១ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **អ៊ី.ធី.អេ ត្រេឌីង ខូ អិលធីឌី** ១៨៨៦

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៧២ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **សាច ខនស្ត្រាក់សិន & ឌីហ្សាញ ខូ អិលធីឌី** ១៨៨៨

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៧៣ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការបង្កើនដើមទុន ចុះបញ្ជីពាណិជ្ជកម្ម និងតម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **អេសអាយធីស៊ី ខិនថេនើរ ឡាញ (ខេមបូឌា)** ១៨៩០

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៧៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ីរលាភ ពាណិជ្ជ** ១៨៩១

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៧៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អេរ្យូលីយ៉ា ខូ អិលធីឌី** ១៨៩៣

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៧៧ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សុខចេង ត្រេឌីង** ១៨៩៥

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៧៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ជេ & អេស ខនស្ត្រាក់សិន** ១៨៩៧

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៧៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ការណាខាន អ៊ិនធើណេសិនណល ស្កូល អបតើរេសិន លីមីធីត** ១៨៩៩

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៨០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខឹវឿ ហ្វាញទើ (ខេមបូឌា)** ១៩០១

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៨១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ត្រូភាស ហ្វាម៉ា អ៊ីមផត អិចផត** ១៩០៣

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៨២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ីង សឺវីស សោម ខបភើសេិន** ១៩០៥

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៨៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស ឆ្វយ សឺវីស** ១៩០៧

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៨៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **គ្លូប៊ល អេវើហ្គ្រីន អូវើស៊ី** ១៩០៩

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៨៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ប៊ី.ស៊ី.អេស ត្រេឌីង & សឺវីស** ១៩១១

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៨៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឡេងឌីង ខូ អិលធីឌី** ១៩១៣

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៩០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ថៃឃួន អ៊ិនវេសម៉ិន & ឌីវេឡុបម៉ិន** ១៩១៥

០៥-០១-២០១៥ -លិខិតបញ្ជាក់លេខ ០០៩៦ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ហាម៉ូនី ផ្លេនថេសិន** ១៩១៧

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១២៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ៊នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ម៉ាន សំអឿន** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៥០២.១៧០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥

លេខៈ ១៤៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៧០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឥស្សរជនចំនួន ០២ រូប ជាអនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ៖

១- ឯកឧត្តម **គ្រាក់ ទីក្រា**

២- ឯកឧត្តម **ឆិន សុខឃួន**

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧រស.១៥០២.១៣១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១៥*

លេខៈ ១៥២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៧១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតួមិជាតិសាសនា រត្តតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ជា ថូន ជាទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស.១៥០២.១៧២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥

លេខ: ១៥១ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៧២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ចំនួន ០៣ រូប ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ តទៅ ÷

១. លោក **សែម សេរីសួស្តី** អនុមន្ត្រី ថ្នាក់លេខ ១៣
២. លោក **ស្វាយស៊ីថា ទិច្ឆិកា** អនុមន្ត្រី ថ្នាក់លេខ ១៤
៣. លោកស្រី **ឌីណា ម៉ូនីកា** អនុមន្ត្រី ថ្នាក់លេខ ១៤។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ២ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌលោកស្រី **ម៉េង ថារី** ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៤ តទៅ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកត.០២១៥.១៣៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥*

លេខៈ ១៥៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៣៣

**យើង**

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស ជាតូបការ**

**ចំពោះ**

**ឧត្តមសេនីយ៍ឯក ខួន ស្រេង**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១៥០២.១៣៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥*

លេខ: ១៤៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៣៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

ឯកឧត្តម អ៊ុំ អ៊ួក

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ១៤៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣រល.១៥០២.១៣៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥*

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៣៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

| | | | | |
|---|---|---|---|---|
| ១- | វរសេនីយ៍ឯក | **អ៊ិន សាធុន** | អត្តលេខ | ០០៣១៦៥ |
| ២- | វរសេនីយ៍ឯក | **ប្រាក់ សោភ័ណ្ឌ** | អត្តលេខ | ០០២៦២៥ |
| ៣- | វរសេនីយ៍ឯក | **ម្លន់ ផល្លា** | អត្តលេខ | ០០៣០៨១ |
| ៤- | វរសេនីយ៍ឯក | **នៅ ស៊ីថន** | អត្តលេខ | ០១០៦១៤ |

ខ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** :

| | | | | |
|---|---|---|---|---|
| - | វរសេនីយ៍ឯក | **នួន ចាន់ធី** | អត្តលេខ | ០១០៦៧៨ |

គ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** :

| | | | | |
|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ត្រី | **ប៉ែន ណារ៉ាវណ្ណ** | អត្តលេខ | ០០៥០១៦ |
| ២- | វរសេនីយ៍ឯក | **អៀង សុផាន់** | អត្តលេខ | ០០១០១៥ |
| ៣- | វរសេនីយ៍ទោ | **ខែម សារ៉ុម** | អត្តលេខ | ០១០៦៩៤ |
| ៤- | វរសេនីយ៍ទោ | **ថុយ ទ្រី** | អត្តលេខ | ០១០៦៤០ |

ឃ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

| | | | | |
|---|---|---|---|---|
| ១- | វរសេនីយ៍ឯក | **គង់ សាមិត្ត** | អត្តលេខ | ០១០៥៩៣ |
| ២- | វរសេនីយ៍ទោ | **ប៊ិន សារ៉ែន** | អត្តលេខ | ០១០៥៨៩ |
| ៣- | វរសេនីយ៍ទោ | **សួន សុន** | អត្តលេខ | ០០៥០០៨ |
| ៤- | វរសេនីយ៍ទោ | **វណ្ណា សុភ័ណ្ឌ** | អត្តលេខ | ០០៤៩៩១ |
| ៥- | វរសេនីយ៍ទោ | **ប៉ែន សារ៉ា** | អត្តលេខ | ០០៣០១០ |
| ៦- | វរសេនីយ៍ទោ | **អាំង សង្ហា** | អត្តលេខ | ០៣៧៣៩២ |
| ៧- | វរសេនីយ៍ទោ | **អាន សារាយ** | អត្តលេខ | ០០១៣៩១ |
| ៨- | វរសេនីយ៍ទោ | **ប៉ែន វណ្ណា** | អត្តលេខ | ០០១០៣៧ |
| ៩- | វរសេនីយ៍ទោ | **បេ សារឿន** | អត្តលេខ | ០១១៤៣៩ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

| | | | | |
|---|---|---|---|---|
| ១០- | វរសេនីយ៍ទោ | ឈុន ម៉ៅ | អត្តលេខ | ០១២៧២៩ |
| ១១- | វរសេនីយ៍ទោ | ជួង សុខសារិន | អត្តលេខ | ០១០៦២៥ |
| ១២- | វរសេនីយ៍ទោ | ច្រាក់ តារា | អត្តលេខ | ០២៩៦៧៣ |
| ១៣- | វរសេនីយ៍ទោ | ព្រហ្ម គីម | អត្តលេខ | ០១៥៨២៦ |
| ១៤- | វរសេនីយ៍ត្រី | ម៉ៅ ទិន័យ | អត្តលេខ | ០១៥៧៩៨ |
| ១៥- | វរសេនីយ៍ត្រី | គុល សារិន | អត្តលេខ | ០២៣០៤០ |
| ១៦- | វរសេនីយ៍ត្រី | សុខ កន្និថា | អត្តលេខ | ០៣០២៥២ |

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

| | | | | |
|---|---|---|---|---|
| ១- | វរសេនីយ៍ទោ | គង់ ហួត | អត្តលេខ | ០១០៦៤១ |
| ២- | វរសេនីយ៍ទោ | សំ សាខន | អត្តលេខ | ០១០៦៤៧ |
| ៣- | វរសេនីយ៍ទោ | ប៉ែន សារិន | អត្តលេខ | ០១០៦៤៩ |
| ៤- | វរសេនីយ៍ទោ | ស្វាយ ហឿន | អត្តលេខ | ០០៣៦១៤ |
| ៥- | វរសេនីយ៍ទោ | អ៊ិន គីមឈាន | អត្តលេខ | ០០៣០០៨ |
| ៦- | វរសេនីយ៍ទោ | ឱុល សុគំណូ | អត្តលេខ | ០០៥១០៨ |
| ៧- | វរសេនីយ៍ទោ | ពេជ្រ ខន | អត្តលេខ | ០០៣៤២៤ |
| ៨- | វរសេនីយ៍ទោ | គីង កទី | អត្តលេខ | ០១៥៧៧៤ |
| ៩- | វរសេនីយ៍ត្រី | ចាន់ ធុលឡា | អត្តលេខ | ០១០៦២៦ |
| ១០- | វរសេនីយ៍ត្រី | សយ វណ្ណសក្តិ | អត្តលេខ | ០៤២០១០ |
| ១១- | វរសេនីយ៍ត្រី | សោ ប៊ុនហួ | អត្តលេខ | ០២២២៥៨ |
| ១២- | វរសេនីយ៍ត្រី | ឡុញ សំ | អត្តលេខ | ០៤១៩៦៨ |
| ១៣- | វរសេនីយ៍ត្រី | នួច ធី | អត្តលេខ | ០២៣០៧៩ |
| ១៤- | វរសេនីយ៍ត្រី | សៀប ឆន់ | អត្តលេខ | ០០៣៧០៣ |
| ១៥- | វរសេនីយ៍ត្រី | ជួន ប៊ុនហួ | អត្តលេខ | ០២១៦៥៣ |
| ១៦- | វរសេនីយ៍ត្រី | ហាស់ លន | អត្តលេខ | ០១១៩៨១ |
| ១៧- | វរសេនីយ៍ត្រី | ឆាយ គីមហួរ | អត្តលេខ | ០១៩៥២៥ |
| ១៨- | វរសេនីយ៍ត្រី | ហាក់ ណារិទ្ធ | អត្តលេខ | ០១៥៧៧៥ |
| ១៩- | វរសេនីយ៍ត្រី | ចាយ សុផល | អត្តលេខ | ០១២៦៣២ |
| ២០- | វរសេនីយ៍ត្រី | មិន ប៊ុនសេង | អត្តលេខ | ០១៥៧៦៤ |
| ២១- | អនុសេនីយ៍ឯក | យ៉ុន សំអឿន | អត្តលេខ | ០៤២៧៥២ |
| ២២- | អនុសេនីយ៍ឯក | ឈុំ សារ៉ន | អត្តលេខ | ០៥៥១៩០ |

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

| | | | | |
|---|---|---|---|---|
| ១- | វរសេនីយ៍ត្រី | សំ សាវឿន | អត្តលេខ | ០០៥១៣២ |
| ២- | វរសេនីយ៍ត្រី | កែវ ធី | អត្តលេខ | ០០៥១២៩ |
| ៣- | វរសេនីយ៍ត្រី | ទ៉ែត ប៊ុនឈឿន | អត្តលេខ | ០១២២៣២ |
| ៤- | វរសេនីយ៍ត្រី | ប៉ាង ហាន | អត្តលេខ | ០០៣៧៣៥ |
| ៥- | វរសេនីយ៍ត្រី | ឱម អ៊ុត | អត្តលេខ | ០១១៩៨៣ |
| ៦- | វរសេនីយ៍ត្រី | ពេជ្រ ស៊ីថា | អត្តលេខ | ០១១៩៨២ |



| | | | | |
|---|---|---|---|---|
| ៧- | វរសេនីយ៍ត្រី | ឈ្លួង ឈួន | អត្តលេខ | ០២១១៣៦៧ |
| ៨- | វរសេនីយ៍ត្រី | កែវ គូមិន្ទ | អត្តលេខ | ០២១៦៧២ |
| ៩- | វរសេនីយ៍ត្រី | ច្រឹក ណារ៉េត | អត្តលេខ | ០៣៥២៣៣ |
| ១០- | វរសេនីយ៍ត្រី | ថៅ សំ | អត្តលេខ | ១៦១២៧៦ |
| ១១- | វរសេនីយ៍ត្រី | តាំង ជ័យវ័ន្ត | អត្តលេខ | ២២៨៤១៩ |
| ១២- | អនុសេនីយ៍ឯក | ចាន់ ធី | អត្តលេខ | ០៣០១៨៥ |
| ១៣- | អនុសេនីយ៍ឯក | ស៊ុំ តារិន | អត្តលេខ | ០៩១០០៨ |
| ១៤- | អនុសេនីយ៍ឯក | ឈួន ស៊ីឃន | អត្តលេខ | ០៩៥៦០២ |
| ១៥- | អនុសេនីយ៍ឯក | ជា សាខន | អត្តលេខ | ០១១៨២៤ |
| ១៦- | អនុសេនីយ៍ឯក | ម៉ុម សារុន | អត្តលេខ | ០១២២៣៦ |
| ១៧- | អនុសេនីយ៍ឯក | ម៉ែន ហាន | អត្តលេខ | ០១៥៨១៨ |
| ១៨- | អនុសេនីយ៍ឯក | ស៊ិន នី | អត្តលេខ | ០១២២៣៣ |
| ១៩- | អនុសេនីយ៍ឯក | ម៉ី ឡុង | អត្តលេខ | ០៣៣៨៤២ |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកត.០២១៥.១៣៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៥

លេខ: ១៥៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៣៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ /០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៦១០ / ៤៦៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ។
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដាក់ឱ្យចូលនិវត្តន៍នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ចំនួន ៣៤ រូប ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ :

| ល.រ | គោត្តនាម និងនាម | ភេទ | អត្តលេខ | មុខតំណែង |
|---|---|---|---|---|
| ១ | នាយឧត្តមសេនីយ៍ **យុន ឈុន្នី** | ប | ០០២២ | អគ្គស្នងការរងនគរបាលជាតិ |
| ២ | នាយឧត្តមសេនីយ៍ **ស៊ឹម សុផល** | ប | ០០៤៣ | អគ្គស្នងការរងនគរបាលជាតិ |
| ៣ | នាយឧត្តមសេនីយ៍ **ពេជ្រ ជីវ័ន** | ប | ០១០២ | អគ្គស្នងការរងនគរបាលជាតិ |
| ៤ | ឧត្តមសេនីយ៍ឯក **ជា សារ៉េត** | ប | ៦១៦៩៧ | អនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ |
| ៥ | ឧត្តមសេនីយ៍ឯក **អៅ គីមឈួន** | ប | ០០៧៤ | ប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ |
| ៦ | ឧត្តមសេនីយ៍ឯក **ឈោង ចរណ៌គួណ៍** | ប | ០៣៨៩ | អនុប្រធានសេនាធិការដ្ឋាន |

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

| | | | | |
|---|---|---|---|---|
| ៧ | ឧត្តមសេនីយ៍ឯក **ឌុង សំអាត** | ប | ០២៤៤ | អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ |
| ៨ | ឧត្តមសេនីយ៍ឯក **ទៅញ គឹមសាន្ត** | ប | ០២២១ | ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ |
| ៩ | ឧត្តមសេនីយ៍ឯក **ត្រាង់ ម៉ៃ** | ប | ០៤៦៧ | អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន |
| ១០ | ឧត្តមសេនីយ៍ទោ**ហ៊ុក គឹមស្រ៊ុន** , | ប | ០១៦២ | អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក |
| ១១ | ឧត្តមសេនីយ៍ទោ **សៅ ម៉ុនធឿន** | ប | ០២២៨ | អនុប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង |
| ១២' | ឧត្តមសេនីយ៍ទោ **ជាម ឆាន់ឈី** | ប | ០០៨៩ | អនុប្រធាននាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ |
| ១៣ | ឧត្តមសេនីយ៍ទោ **ឡុង យឿន** | ប | ១២៧៤ | អនុប្រធាននាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ |
| ១៤ | ឧត្តមសេនីយ៍ទោ **ជា សាន** | ប | ០៣៣៩ | អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន |
| ១៥ | ឧត្តមសេនីយ៍ទោ **អែល សំណាង** | ប | ១៥០៩ | ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ |
| ១៦ | ឧត្តមសេនីយ៍ត្រី **ឆឹម ផន** | ប | ០១៦៩ | នាយនគរបាលនៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ១៧ | ឧត្តមសេនីយ៍ត្រី **មួន អឿន** | ប | ១០៣៨ | ស្នងការរងហិរញ្ញកិច្ច និងភស្តុភារ នៃសេនាធិការដ្ឋាន |
| ១៨ | ឧត្តមសេនីយ៍ត្រី **ហ៊ឹង ចន្ទតារា** | ប | ០២៨២ | អនុប្រធាននាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ |
| ១៩ | ឧត្តមសេនីយ៍ត្រី **សោម ចាន់នី** | ប | ១៥៦៣១ | អនុប្រធាននាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ |
| ២០ | ឧត្តមសេនីយ៍ត្រី **ស៊ិន ណៃឌុយ** | ប | ០៧៧៩ | អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន |
| ២១ | ឧត្តមសេនីយ៍ត្រី **សួន សុគន្ធ** | ប | ០៦៧៥ | អនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើស - សេដ្ឋកិច្ច |
| ២២ | ឧត្តមសេនីយ៍ត្រី **នង សារី** | ប | ០៦៨២ | អនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើស - សេដ្ឋកិច្ច |
| ២៣ | ឧត្តមសេនីយ៍ត្រី **ស្លា សំណាង** | ប | ០២៤១ | អនុប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម |
| ២៤ | ឧត្តមសេនីយ៍ត្រី **នង សុផល** | ប | ០៧៤១ | អនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ |
| ២៥ | ឧត្តមសេនីយ៍ត្រី **ឃិន ហាន** | ប | ១៣៦៥ | អនុប្រធាននាយកដ្ឋានអង្គរក្ស |
| ២៦ | ឧត្តមសេនីយ៍ត្រី **ឡាយ អុល** | ប | ១៣៧៨ | អនុប្រធាននាយកដ្ឋានអង្គរក្ស |
| ២៧ | ឧត្តមសេនីយ៍ត្រី **សេង សារី** | ប | ០១៥១ | អនុប្រធានអង្គភាពអន្តរាគមន៍ |
| ២៨ | ឧត្តមសេនីយ៍ត្រី **ជា ឌុន** | ប | ០៤១៧ | អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ |
| ២៩ | ឧត្តមសេនីយ៍ត្រី **រស់ ចិន្តា** | ប | ១៤៧៦ | អនុប្រធាននាយកដ្ឋានស្រាវជ្រាវនិងត្រួតពិនិត្យនៃអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធ ប្រឆាំងគ្រឿងញៀន |

| | | | | |
|---|---|---|---|---|
| ៣០ | ឧត្តមសេនីយ៍ត្រី **ស៊ឹម ហ៊ី** | ប | ០៦០២ | អនុប្រធាននាយកដ្ឋាននគរបាលការពារ |
| ៣១ | ឧត្តមសេនីយ៍ត្រី **ធឹម ខន្ស** | ប | ០២៦៦ | អនុប្រធាននាយកដ្ឋានវិទ្យុទាក់ទង |
| ៣២ | ឧត្តមសេនីយ៍ត្រី **ផន ផៃខ** | ប | ៣៦២១ | ស្នងការរងនៃស្នងដ្ឋាននគរបាលរាជធានីភ្នំពេញ |
| ៣៣ | ឧត្តមសេនីយ៍ត្រី **គីច ចន្ទម៉ឹន** | ប | ០៥១២ | ស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង |
| ៣៤ | ឧត្តមសេនីយ៍ត្រី **សួស សុធាព** | ប | ៦២៧៤០ | អនុប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ |

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០២១៥/១៣៧

លេខ: ១៥៥ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៥*

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៣៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**ជាកិត្តិយសបច្ឆាមរណៈ**

**ចំពោះ**

**សពឯកឧត្តម ពោន ពន្លឺ**

**នូវ**

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

៣.វ.ល-១៥០២.១៣៨
**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ០៣៧/១៥ រ.ចច
រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ត្រាស់បង្គាប់

តែងតាំង :

ឯកឧត្តមឧត្តមសេនីយ៍ឯក **លីវ ម៉ូវ** អត្តលេខ ០៤០១

ជា

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧ រ.ណ. ១៥០២. ១៧៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៥

លេខៈ ១៦១ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៣៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ដល់ឯកឧត្តមឧត្តមសេនីយ៍ទោ **គឹម សុខុន** អត្តលេខ ១២៦៤៧ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ១៥៨ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

៣៧៧.១៥០២.១៤០

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៤០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ដល់លោកឧត្តមសេនីយ៍ត្រី **ផាន់ សុផល** អត្តលេខ ០៧៨៤ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ១៤៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២ ៤ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៧រាល.១៥០២.១៤១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៥*

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៤១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ម៉ា ស៊ីនហួត** ជាអនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន ជំនួសឯកឧត្តម **សួត សំបូរ** ដែលបានទទួលមរណភាព ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរណ.១៥០២.១៤២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥*

លេខ: ១៦៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៤២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ភូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំងមន្ត្រីរាជការ នៃក្រសួងយុត្តិធម៌ ចំនួន ០២រូប ៖

១. ឯកឧត្តម **ម៉ែន ទិស្ស** ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល

២. ឯកឧត្តម **ម៉ុន សាខាត់** ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ភ្នំពេញ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧.១៥០២.១៤៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៥*

លេខ: ១៦០ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៥/១៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេរីវឌ្ឍន៍** :
- ១- ឧត្តមសេនីយ៍ទោ Luu Đuc Huy
- ២- ឧត្តមសេនីយ៍ត្រី Phan Anh Viêt
- ៣- ឧត្តមសេនីយ៍ត្រី Phan Hai Quan

ខ- គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា** :
- ១- វរសេនីយ៍ឯក Đo Thang Lam
- ២- វរសេនីយ៍ឯក Pham Van Thanh
- ៣- វរសេនីយ៍ឯកបំរុង Nguyen Đinh Khoa
- ៤- វរសេនីយ៍ត្រី Nguyen Van Nam

គ- គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **ធិបឌិន្ទ** :
- ១- វរសេនីយ៍ឯក Le Duy Dan
- ២- វរសេនីយ៍ឯក Phan Van Phong
- ៣- អនុសេនីយ៍ឯក Pham Hong Thanh

ចរស. ១៥០២. ១៤៥

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៥

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ....០០៧/១៥..... រ. ចច
រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៥
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រេង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ១៥ អនក្រ.បក**

# អនុក្រឹត្យ
# ស្ដីពី
# ការកែសម្រួលបៀវត្សមូលដ្ឋាននិងការបើកផ្ដល់បៀវត្ស ដល់មន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៨៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីការកែសំរួលប្រព័ន្ធបៀវត្សនគរបាលជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងដើម្បីរៀបចំការកំណត់បៀវត្សមូលដ្ឋាន និង ការបើកផ្ដល់បៀវត្សមូលដ្ឋាននិងរបបឧបត្ថម្ភផ្សេងៗដល់មន្ត្រីនគរបាលជាតិកម្ពុជា។

**មាត្រា២ .–**

អនុក្រឹត្យនេះ មានគោលដៅកំណត់៖

- កម្រិតសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីនគរបាលជាតិកម្ពុជា
- ការបើកផ្តល់បៀវត្សមូលដ្ឋាននិងរបបឧបត្ថម្ភផ្សេងៗរបស់មន្ត្រីនគរបាលជាតិតាមប្រព័ន្ធធនាគារ លើកលែងមន្ត្រីនគរបាលជាតិ ដែលមានការអនុញ្ញាតដោយឡែកដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៣ .–**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីនគរបាលជាតិកម្ពុជា។

**មាត្រា៤ .–**

បៀវត្សមូលដ្ឋានរបស់មន្ត្រីនគរបាលជាតិកម្ពុជា ត្រូវបានរៀបចំបែងចែកតាមលំដាប់នៃឋានន្តរស័ក្តិ និងត្រូវបានផ្តល់នូវកម្រិតសន្ទស្សន៍ ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | ឋានន្តរស័ក្តិ | កម្រិតសន្ទស្សន៍បៀវត្សមូលដ្ឋាន |
|---|---|---|
| ១ | នាយឧត្តមសេនីយ៍ | ៥៥០ |
| ២ | ឧត្តមសេនីយ៍ឯក | ៥៣១ |
| ៣ | ឧត្តមសេនីយ៍ទោ | ៥១៣ |
| ៤ | ឧត្តមសេនីយ៍ត្រី | ៤៩៦ |
| ៥ | វរសេនីយ៍ឯក | ៤៧៩ |
| ៦ | វរសេនីយ៍ទោ | ៤៦១ |
| ៧ | វរសេនីយ៍ត្រី | ៤៤៣ |
| ៨ | អនុសេនីយ៍ឯក | ៤០៧ |
| ៩ | អនុសេនីយ៍ទោ | ៣៨០ |
| ១០ | អនុសេនីយ៍ត្រី | ៣៤៤ |
| ១១ | នាយចំណង់ | ៣៣១ |
| ១២ | ព្រឹន្ទបាលឯក | ៣១៨ |
| ១៣ | ព្រឹន្ទបាលទោ | ៣០០ |
| ១៤ | ពលបាលឯក | ២៨៤ |
| ១៥ | ពលបាលទោ | ២៧៤ |
| ១៦ | ពលបាលត្រី | ២៦៥ |

កម្រិតសន្ទស្សន៍បៀវត្សមូលដ្ឋានខាងលើ ត្រូវចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥។

**មាត្រា៥ .-**

តម្លៃឯកតាសន្ទស្សន៍សម្រាប់អនុវត្តនិងការកែប្រែតម្លៃឯកតាសន្ទស្សន៍ ត្រូវអនុវត្តតាមអនុក្រឹត្យស្តីពីតម្លៃឯកតានៃសន្ទស្សន៍សម្រាប់បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល។

**មាត្រា៦ .-**

មន្ត្រីនគរបាលជាតិដែលមានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់វិភាជន៍គ្រួសារ ប្រាក់ហូបប្រចាំថ្ងៃ និងរបបអង្គប្រចាំខែ ព្រមទាំងរបបឧបត្ថម្ភផ្សេងទៀត ត្រូវស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- កំពុងបំពេញការងារក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- កំពុងផ្លាស់ប្តូរកន្លែងធ្វើការនិងកំពុងធ្វើដំណើរទៅកាន់មុខតំណែងនៅក្នុងឬក្រៅប្រទេស
- កំពុងបំពេញការសិក្សាក្នុងឬក្រៅប្រទេសតាមតម្រូវការរបស់នគរបាលជាតិ
- មន្ត្រីនគរបាលជាតិពលី ពិការ មរណៈ និវត្តជន បាត់បង់សមត្ថភាពការងារដែលមិនទាន់ផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្ត
- មន្ត្រីនគរបាលជាតិដែលទទួលការអនុញ្ញាតច្បាប់ក្នុងធុរៈផ្ទាល់ រយៈពេលសម្រាកព្យាបាលជម្ងឺ និងបាត់ខ្លួនក្នុងបេសកកម្ម។

**មាត្រា៧ .-**

ការបញ្ឈប់ការបើកផ្តល់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់វិភាជន៍គ្រួសារ ប្រាក់ហូបប្រចាំថ្ងៃ និងរបបអង្គប្រចាំខែ ព្រមទាំងរបបឧបត្ថម្ភផ្សេងទៀត ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងករណីដូចខាងក្រោម៖

- មន្ត្រីនគរបាលជាតិដែលសុំលាឈប់ពីការងារដោយមានការអនុញ្ញាត
- មន្ត្រីនគរបាលជាតិដែលមានប្រកាសបណ្តេញចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- មន្ត្រីនគរបាលជាតិដែលអវត្តមានគ្មានការអនុញ្ញាតឬហួសកំណត់ដោយសម្អាងលើប្រធានស័ក្តិដែលមិនសមស្រប
- មន្ត្រីនគរបាលជាតិពលី ពិការ មរណៈ និវត្តជន បាត់បង់សមត្ថភាពការងារដែលបានផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្តរួចហើយ
- មន្ត្រីនគរបាលជាតិដែលមានសាលក្រមរបស់តុលាការបញ្ជាក់ថាជាទណ្ឌិត។

**មាត្រា៨ .-**

របបឧបត្ថម្ភផ្សេងៗរបស់មន្ត្រីនគរបាលជាតិក្រៅពីបៀវត្សមូលដ្ឋាន ត្រូវបន្តអនុវត្តរហូតដល់មានការកែប្រែជាថ្មី។

**មាត្រា៩ .-**

បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់វិភាជន៍គ្រួសារ ប្រាក់ហូបប្រចាំថ្ងៃ រួមទាំងរបបអង្គប្រចាំខែដែលគិតជាសាច់ប្រាក់ត្រូវបើកផ្តល់ដល់មន្ត្រីនគរបាលជាតិតាមប្រព័ន្ធធនាគារ។

ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវសហការរៀបចំការបើកផ្តល់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់វិភាជន៍គ្រួសារ ប្រាក់ហូបប្រចាំថ្ងៃ រួមទាំងរបបអង្គប្រចាំខែគិតជាសាច់ប្រាក់ដល់មន្ត្រីនគរបាលជាតិតាមប្រព័ន្ធធនាគារឱ្យបានរួចរាល់ក្នុងឆ្នាំ២០១៥។

ក្នុងករណីសេវាធនាគារនៅមិនទាន់មាននៅជិតអង្គភាព ដើម្បីបង្កភាពងាយស្រួលដល់ការបើកផ្តល់បៀវត្សដល់មន្ត្រីនគរបាលជាតិម្នាក់ៗ ក្រសួងមហាផ្ទៃនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសារាចរណែនាំស្តីពីការបើកផ្តល់បៀវត្សពីធនាគារដល់មន្ត្រីនគរបាលជាតិនៅតាមអង្គភាពនោះ។

**មាត្រា១០ .-**

អនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលប្រាក់បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីនគរបាលជាតិ ត្រូវទុកជានិរាករណ៍។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

| | | |
|---|---|---|
| **ឧបនាយករដ្ឋមន្ត្រី**<br>**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** |
| **ស ខេង** | **អូន ព័ន្ធមុនីរ័ត្ន** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៦៥អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន១៩១ ៣០០ ០០០រៀល (មួយរយកៅសិបមួយលានបីរយពាន់រៀលគត់) ពីជំពូក០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) ជូនក្រសួងមុខងារសាធារណៈ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ចំណាយតាំងពិពណ៌និងការប្រជុំតុមូលនៅប្រទេសកូរ៉េ។

**មាត្រា៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៨៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **តូច ពិដោរឡា** អត្តលេខ ៣៤០៨៣ នាយនគរបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៨៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពប្រធានផ្នែកក្នុងរចនាសម្ព័ន្ធ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៣/១៩១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

តែងតាំងសមាសភាពជាប្រធានផ្នែកក្នុងរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- លោក **ឡាយ សុខគីម** | ជាប្រធានផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២- លោកស្រី **ទេព ស៊ីណារ៉ាត** | ជាប្រធានផ្នែកអនុវត្តគោលនយោបាយ មានឋានៈស្មើប្រធាននាយកដ្ឋានបន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣- លោក **លឹម ម៉ូរ៉ា** | ជាប្រធានផ្នែកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..១៨២..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៣/១៩១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

តែងតាំងសមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជនដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត **ហង់ ជួន ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធានប្រចាំការ |
| ៤- ឯកឧត្តម **ម៉ម ប៊ុនហេង** | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| ១- ឯកឧត្តម **អ៊ុន ទីរជាតិ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២- ឯកឧត្តម **តេង សាវង្ស** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៣- លោកជំទាវ **ដាំ ដារីនី** | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិកា |
| ៤- ឯកឧត្តម **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- លោកជំទាវ **សុខ ទិត្យាយ** | រដ្ឋលេខាធិការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិកា |
| ៦- លោកជំទាវ **តឹករ៉េត អំរេខ** | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិកា |
| ៧- ឯកឧត្តម **ប៉ាន ប៊ុនធឿន** | រដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ៨- ឯកឧត្តម **សរ សុវណ្ណា** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៩- ឯកឧត្តម **ពេជ សោភ័ន** | រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០- លោកជំទាវ **សេង វណ្ណាសាយ** | រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិកា |
| ១១-ឯកឧត្តម **តូច ចាន់កុសល** | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១២-ឯកឧត្តម **ភាន ច័ន្ទមេត្តា** | រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៣-លោកជំទាវ **កុប ម៉ារីយ៉ាស់** | រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិកា |
| ១៤-ឯកឧត្តម **អ៊ិន ចន្ថា** | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៥-ឯកឧត្តម **សោម សុគន្ធ** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៦-ឯកឧត្តម **មុត ខៀវ** | រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៧-ឯកឧត្តម **សុះ មុះសិន** | រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា | សមាជិក |

| | | |
|---|---|---|
| ១៨- ឯកឧត្តម **កើត រិទ្ធ** | រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | សមាជិក |
| ១៩- លោកជំទាវ **ហោ ម៉ាលីន** | រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិកា |
| ២០- ឯកឧត្តម **ហេង សុខគង់** | រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ២១- ឯកឧត្តម **ឌិត ទីណា** | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២២- ឯកឧត្តម **ប៉ាក់ សុខុម** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ២៣- ឯកឧត្តម **ពិត ចំណាន** | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២៤- ឯកឧត្តម **ស៊ាន ម៉ូរ៉ាត** | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២៥- ឯកឧត្តម **ណុះ ស្លេះ** | អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២៦- ឯកឧត្តម **ឃួន ផុនរតនៈ** | អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៧- ឯកឧត្តម **សឹម យ៉ារ៉ែន** | អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ២៨- ឯកឧត្តម **មាស សុភ័ណ្ឌ** | អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ២៩- ឯកឧត្តម **ឈឿន ប៊ុណ្ណារ័ត្ន** | អនុរដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ | សមាជិក |
| ៣០- ឯកឧត្តម **ពៅ ប៉ូលីណែល** | អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ៣១- ឯកឧត្តម **មាស វិរិទ្ធ** | អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | សមាជិក |
| ៣២- ឯកឧត្តម **តូច ជឿន** | អគ្គលេខាធិការ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន | សមាជិក |
| ៣៣- លោក **រស់ សីលវ៉ាត់** | អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ | សមាជិក |
| ៣៤- លោកស្រី **ស្រួយ សុជាតិ** | សមាជិកគណៈកម្មាធិការកណ្តាលសហភាព សហព័ន្ធយុវជនកម្ពុជា | សមាជិកា |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងបន្ថែមសមាសភាព នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីវិសោធនកម្ម មាត្រា ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១១/៩៤១ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ ស្តីពីវិសោធនកម្ម មាត្រា ១ នៃរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីវិសោធនកម្ម មាត្រា ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

- បានឃើញអនុក្រឹត្យលេខ ៩៦៤ អនក្រ.តត ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៣ ស្ដីពីការកែសម្រួលសមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- យោងតាមការចាំបាច់ ។

**សម្រេច**

**មាត្រា ១** ៖ ត្រូវបានតែងតាំង **ឯកឧត្ដម វ៉ាន សំអឿន** ជាអនុប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
សមាជិកអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
ដូចមាត្រា ២
រាជកិច្ច
ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៨៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

### សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ** ចំនួន ០២គ្រឿង ជូនមន្ត្រីរាជការ និងសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមកសាង និងអភិវឌ្ឍន៍ក្នុងមូលដ្ឋាន នៅឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

១- លោក **ឡេន ថារី** ជំទប់ទី២ ឃុំដារ

២- លោក **ថាំង សារឿន** សប្បុរសជន

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៨៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

### សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន ៧៣គ្រឿង ប្រគេនព្រះសង្ឃ និងជូនមន្ត្រីរាជការ ចំនួន ៧៣រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមកសាង និងអភិវឌ្ឍន៍ក្នុងមូលដ្ឋាន នៅឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

| | |
|---|---|
| ១-ព្រះតេជគុណ លី សារុន | ព្រះចៅអធិការស្តីទីវត្តគីរីវ័ន្តស្ថាន |
| ២-លោក ញ៉ឹក នៅ | ប្រធានការិយាល័យធម្មការ និងសាសនាស្រុកមេមត់ |
| ៣-លោក អ៊ឹង សំអុល | នាយករដ្ឋបាលសាលាស្រុកមេមត់ |
| ៤-កញ្ញា ទី លីហ្វាន់ | មន្ត្រីការិយាល័យកិច្ចការនារីស្រុកមេមត់ |
| ៥-លោក ម៉ើ ប៉េះ | សមាជិកភូមិសាឡង់ ២ |

**ខ-មេដាយប្រាក់ការងារ**

| | |
|---|---|
| ១-លោក ប៉េះ ចំរើន | ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំដារ |
| ២-លោក ទូច ម៉េងហៃ | នាយកវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន ដារ |
| ៣-លោក ណៅ ឆាទី | នាយកសាលាអនុវិទ្យាល័យតេជោសែន ផ្កាកសំរោង |
| ៤-លោក អៀង ឡេង | នាយកអនុវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន សាឡង់ ២ |
| ៥-លោក ប៉ា គីម | នាយកសាលាបឋមសិក្សាដារ |
| ៦-លោកស្រី អ៊ឹម វុឌ្ឍនី | នាយកសាលាបឋមសិក្សាតេជោសែន ផ្កាកសំរោង |
| ៧-លោក សេន ថុន | នាយករងវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន ដារ |
| ៨-លោក សុះ អ៊ីសា | នាយករងបឋមសិក្សាតេជោសែន ផ្កាកសំរោង |

| | |
|---|---|
| ៩-លោក សេង ប៊ុនធឿន | ស្មៀនឃុំ |
| ១០-លោក មាស សុផល | សប្បុរសជន |
| ១១-លោក ខុញ វន | សប្បុរសជន |
| ១២-លោក ម៉ៅ ចយ | សប្បុរសជន |
| ១៣-លោក សាំង ចុង | មេភូមិសំរោងជើង |
| ១៤-លោក អ៊ុម ខ្មៅ | សមាជិកភូមិសំរោងជើង |
| ១៥-លោក ឆុន ធឿន | សប្បុរសជន |
| ១៦-លោក សំរិទ្ធិ អឿន | សប្បុរសជន |
| ១៧-លោក លី ស៊ុល | មេភូមិចំការគរ |
| ១៨-លោក មួន ចាន់ថា | សប្បុរសជន |
| ១៩-លោក សេន សិត | មេភូមិ ៧ មករា |
| ២០-លោក ជេត សេន | សមាជិកភូមិ ៧ មករា |
| ២១-លោកស្រី លាស់ ណារ | សប្បុរសជន |
| ២២-លោក យឹម ជឹម | អនុប្រធានភូមិដារផ្សារ |
| ២៣-លោក ចាន់ ថន | សមាជិកក្រុមប្រឹក្សាឃុំដារ |
| ២៤-លោក គង់ ដន | មេភូមិដារជើង |
| ២៥-លោក ផៃ អ៊ី | សមាជិកភូមិដារជើង |
| ២៦-លោក អ៊ុង ឈុនអេង | មេភូមិទ្រៀក |
| ២៧-លោក សុន សយ | សមាជិកភូមិស្រែជ្រាំ |
| ២៨-លោក យឹម សំអាង | មេភូមិមែកពុក |
| ២៩-លោក គីម វ៉ាន់ឌី | មេភូមិសាឡង់ ២ |
| ៣០-លោកស្រី សី កាន | សមាជិកភូមិដាត្បូង |
| ៣១-លោក ញ៉ឹកឆែមវុទ្ធី | សប្បុរសជន |
| ៣២-លោក អ៊ិន វិជ្ជាវុធ | សប្បុរសជន |
| ៣៣-លោក ខៀវ ចាន់ | សប្បុរសជន |
| ៣៤-លោក ជឹម ចាន់នី | សប្បុរសជន |

**គ-មេដាយសំរឹទ្ធការងារ**

| | |
|---|---|
| ១-លោកស្រី ញ៉ឹម ផល្លា | សមាជិកក្រុមប្រឹក្សាឃុំដារ |
| ២-លោកស្រី ហ៊ីង វ៉ាន | សមាជិកក្រុមប្រឹក្សាឃុំដារ |
| ៣-លោក ង៉ែ តាមុត | ប្រធានគណៈកម្មការអាចារ្យវត្តគីរីវ័ន្ត ស្ពាន |
| ៤-លោក យ៉ូវ សំ | ប្រធានគណៈកម្មការអាចារ្យវត្តសុវណ្ណារាម ដារ |
| ៥-លោក លឹម នឹន | សមាជិកគណៈកម្មការអាចារ្យវត្តគីរីវ័ន្ត ស្ពាន |
| ៦-លោក ប្រេះ យន់ | អាចារ្យវត្តគីរីវ័ន្ត ស្ពាន |
| ៧-លោក ហេង អៀង | អាចារ្យវត្តគីរីវ័ន្ត ស្ពាន |
| ៨-លោក ឡ ហែល | អាចារ្យវត្តគីរីវ័ន្ត ស្ពាន |
| ៩-លោក ម៉ៅ មួន | សប្បុរសជន |

| | | | |
|---|---|---|---|
| ១០-លោក | រស់ | នី | សប្បុរសជន |
| ១១-លោក | លី | ម៉េងហួ | នាយកសាលាបឋមសិក្សាស្ពាន |
| ១២-លោក | ជឹម | ហុន | សប្បុរសជន |
| ១៣-លោក | ម៉ាន់ | មិន | សប្បុរសជន |
| ១៤-លោក | ម៉ាន់ | មឿន | សប្បុរសជន |
| ១៥-លោក | អ៊ុង | វ៉ាន់ | សប្បុរសជន |
| ១៦-លោក | ទូច | ជួត | អនុប្រធានភូមិដារកណ្ដាល |
| ១៧-លោក | សូ | ញាណ | សប្បុរសជន |
| ១៨-លោក | សួន | សៀម | សប្បុរសជន |
| ១៩-លោក | សុំ | ហិន | សមាជិកភូមិទ្រៀក |
| ២០-លោក | ហ៊ីម | អុន | សប្បុរសជន |
| ២១-លោក | ជិន | អឿន | មេភូមិស្រែជ្រាំ |
| ២២-លោក | យ៉ាន | វ៉ា | សមាជិកភូមិម៉ែកពុក |
| ២៣-លោក | ធួក | សេងអ៊ាម | សប្បុរសជន |
| ២៤-លោក | យេ | សុន | សប្បុរសជន |
| ២៥-លោក | សែ | សែម | មេភូមិសាឡង់ ១ |
| ២៦-លោក | ណាង | គឹមស៊ាន | អនុភូមិសាឡង់ ១ |
| ២៧-លោក | ស៊ាវ | ខាន់ | នាយកសាលាបឋមសិក្សាសាឡង់ ១ |
| ២៨-លោក | សរ | អ៊ុន | សប្បុរសជន |
| ២៩-លោក | សេន | តារី | អនុប្រធានតាក៏មភូមិ ៧ មករា |
| ៣០-លោក | បាក់ | ហេស់ | តាក៏មភូមិបុរីតេជោសែន |
| ៣១-លោក | អ៊ុង | វ៉ាន់ | តាក៏មភូមិស្នួច |
| ៣២-លោក | សឹម | ម៉ាត់ | ភូឈួយទី ១ |
| ៣៣-លោក | តាំ | អូស្មាន | ហាក៏ម |
| ៣៤-លោក | កសឹម | ស្លេម៉ាន | សប្បុរសជន |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៣ខែ កុម្ភៈ ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរក្របខ័ណ្ឌ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូនឧត្តមសេនីយ៍ត្រី **ខួន ទិទ្ធ** អត្តលេខ០០៤៣៣៣ នាយទាហានការពារផ្ទាល់ កងពលតូចលេខ៧០ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នទៅបម្រើ ការងារក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៩៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ

## សម្រេច

**មាត្រា១.**.បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអ្នកស្រី **ហ៊ិញ សោភា** ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ ទទួលបានលទ្ធផលល្អប្រសើរ ។

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីផ្ទេរ និងសម្រួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាបកេម្ម និងសិប្បកម្ម

## សម្រេច

**មាត្រា ១** : ផ្ទេរ និងសម្រួលភារកិច្ចលោក **សឹន សូថា** ពីអគ្គនាយករងនៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ឱ្យបំពេញមុខងារជា អគ្គនាយករង នៃអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ជំនួសឯកឧត្តម **សុន សេងហួត** ដែលបានចូលនិវត្តន៍។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ [illegible] ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា១.** បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូន NIK MOHD NASRUN BIN NIK ABDULLAH ដែលបានចូលរួមជួយកសាងវិហារធំឥស្លាម Al-Serkal ដែលមានទីតាំងស្ថិតនៅបឹងកក់ ( ក្រោយសណ្ឋាគារភ្នំពេញ ) សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៩៤.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

ប្រគល់ភារកិច្ចជូនលោកស្រី **អ៊ិត មល្លិកា** ឱ្យបំពេញមុខងារជាប្រធានផ្នែកទទួលបន្ទុកច្បាប់ពាណិជ្ជកម្ម និងធុរកិច្ច នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៨៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

**សម្រេច**

**មាត្រា ១** : តែងតាំងលោក ឃោ ម៉េរ ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៥៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១._**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយស សុវត្ថារា** តាបលំដាប់ថ្នាក់ ប្រគេនព្រះតេជគុណ ចំនួន ០២អង្គ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ ឧបដ្ឋានសាលា និងសមិទ្ធផលនានាជាច្រើនទៀត នៅ**វត្តពោធិសត្ថារាម** (ហៅវត្តហុងឡាំ) ស្ថិតនៅក្នុងសង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ដែលមានរាយព្រះនាមដូចខាងក្រោម :

**ក. មេដាយសុវត្ថារាថ្នាក់ធិបឌិន្ទចំនួន ០១ គ្រឿង ប្រគេន**

ព្រះតេជគុណធម្មរក្ខិតោ **លឹម ធ្វី** គង់នៅវត្តពោធិសត្ថារាម បច្ច័យចំនួន ១៣១.៤៤០ ដុល្លារ

**ខ. មេដាយសុវត្ថារាថ្នាក់សេនាចំនួន ០១ គ្រឿង ប្រគេន**

ព្រះតេជគុណបញ្ញាបទីបោ **ធ្លាក់ ឃិន** ព្រះចៅអធិការវត្តពោធិសត្ថារាម បច្ច័យចំនួន ៤៨.២៥៨ ដុល្លារ

**មាត្រា ២ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:..១៧៧..អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជនចំនួន ១០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ ឧបដ្ឋានសាលា និងសមិទ្ធផលនានាជាច្រើនទៀត នៅ**វត្តពោធិសព្វារាម** ( ហៅវត្តហុងឡាំ ) ស្ថិតនៅក្នុងសង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ដែលមានរាយនាមដូចខាងក្រោម :

**ក. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៧ គ្រឿង ផ្តល់ជូន :**

| | | |
|---|---|---|
| ១-ឧបាសក **ឆេង ស៊ី** | សប្បុរសជននៅខេត្តក្រចេះ | ថវិកាចំនួន ៩.៦៨៦ ដុល្លារ |
| ២-ឧបាសិកា **ហោ គីមថេន** | សប្បុរសជននៅខេត្តក្រចេះ | ថវិកាចំនួន ៨.១០២ ដុល្លារ |
| ៣-លោកស្រី **នូ សុជាតិ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៨.០០០ ដុល្លារ |
| ៤-ឧបាសិកា **គួយ គីមឡេង** | សប្បុរសជននៅខេត្តក្រចេះ | ថវិកាចំនួន ៧.២១០ ដុល្លារ |
| ៥-ឧបាសិកា **ហេង ស៊ីថា** | សប្បុរសជននៅខេត្តក្រចេះ | ថវិកាចំនួន ៦.៨៤៥ ដុល្លារ |
| ៦-ឧបាសិកា **ហ៊ីវ សុផល** | សប្បុរសជននៅខេត្តកំពត | ថវិកាចំនួន ៦.០០០ ដុល្លារ |

៧-លោក **សុខ ចន** សប្បុរសជននៅខេត្តក្រចេះ ថវិកាចំនួន ៥.000 ដុល្លារ

**ខ. មេដាយសិរីវឌ្ឍិស្ថាបនាជាតិចំនួន ០៣ គ្រឿង ផ្ដល់ជូន :**

១-ឧបាសក **ឈាង ចារ** សប្បុរសជននៅខេត្តក្រចេះ ថវិកាចំនួន ៤.៦៤០ ដុល្លារ

២-ឧបាសិកា **ស៊ុច សុផា** សប្បុរសជននៅខេត្តក្រចេះ ថវិកាចំនួន ៣.000 ដុល្លារ

៣-លោក **គិន បូផាន់** សប្បុរសជននៅខេត្តក្រចេះ ថវិកាចំនួន ៣.000 ដុល្លារ

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__**កន្លែងទទួល :**__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនឹងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ២៥រូប ដែលបានបរិច្ចាគ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ និកុដិ នៅ**វត្តប្រាសាទគោលវង្សី** ស្ថិតនៅក្នុងឃុំគោល ស្រុកអង្គរជុំ ខេត្តសៀមរាប ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៧ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណវិជិរប្បញ្ញោ | **សូម សាម៉ន** | ព្រះអនុគុណស្រុកអង្គរជុំ | បច្ច័យចំនួន ១២.០០០ ដុល្លារ |
| ២-ព្រះតេជគុណ | **សោម សេក** | ព្រះចៅអធិការវត្តប្រាសាទគោលវង្សី | បច្ច័យចំនួន ១២.០០០ ដុល្លារ |
| ៣-លោកស្រី | **យូ សុភា** | ប្រធានមន្ទីរកិច្ចការនារីខេត្ត | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ៤-លោក | **លុក ផុស** | អភិបាលស្រុកអង្គរជុំ | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ៥-លោកស្រី | **អ៊ីុង ផល្លី** | អភិបាលរងស្រុកអង្គរជុំ | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ៦-លោក | **ខុន ចាន់ឌី** | សមាជិកក្រុមប្រឹក្សាស្រុកអង្គរជុំ | ថវិកាចំនួន ១០.៥០០ ដុល្លារ |
| ៧-លោក | **ណោង ហ៊ុល** | មេឃុំគោល | ថវិកាចំនួន ១០.៥០០ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០២ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-លោក | **ញ៉យ ចិក** | អាចារ្យវត្តប្រាសាទគោលវង្សី | ថវិកាចំនួន ៥.៦០០ ដុល្លារ |

| | | | |
|---|---|---|---|
| ២-លោក **ណុយ ឃឿញ** | គណៈកម្មការវត្តប្រាសាទគោលវង្សី | ថវិកាចំនួន | ៥.២០០ ដុល្លារ |

**គ-‌ មេដាយសិរីវឌ្ឍិស្ថាបនាជាតិចំនួន ១៦ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-លោក **ញ៉យ តឿន** | មេភូមិខាន់ស | ថវិកាចំនួន | ១.៨៥០ ដុល្លារ |
| ២-លោក **យ៉ន់ ឡឿន** | មេភូមិតាគួយ | ថវិកាចំនួន | ១.៨២៥ ដុល្លារ |
| ៣-លោក **ស្តៃ ខួន** | មេភូមិអំពិលធ្លង់ | ថវិកាចំនួន | ១.៨១៥ ដុល្លារ |
| ៤-លោក **និត ណុត** | មេភូមិគោល | ថវិកាចំនួន | ១.៧០០ ដុល្លារ |
| ៥-លោក **អូ ខួន** | មេភូមិខ្ទាវ | ថវិកាចំនួន | ១.៦៨០ ដុល្លារ |
| ៦-លោក **រី ម៉ប់** | មេភូមិព្រៃអា | ថវិកាចំនួន | ១.៦៥០ ដុល្លារ |
| ៧-លោក **ហេង ហើល** | មេភូមិដូនមៀវ | ថវិកាចំនួន | ១.៦៣៥ ដុល្លារ |
| ៨-លោក **ព្រឹម ខុំ** | គណៈកម្មការវត្តប្រាសាទគោលវង្សី | ថវិកាចំនួន | ១.៥០០ ដុល្លារ |
| ៩-លោក **សូ ដាត** | គណៈកម្មការវត្តប្រាសាទគោលវង្សី | ថវិកាចំនួន | ១.៤៨៥ ដុល្លារ |
| ១០-លោក **ព្រិន ប្រុង** | គណៈកម្មការវត្តប្រាសាទគោលវង្សី | ថវិកាចំនួន | ១.៤៥០ ដុល្លារ |
| ១១-លោក **ធន់ ឆើម** | គណៈកម្មការភូមិខ្ទាវ | ថវិកាចំនួន | ១.៤៣០ ដុល្លារ |
| ១២-លោក **តឿន សៅ** | គណៈកម្មការភូមិអំពិលធ្លង់ | ថវិកាចំនួន | ១.៣៧៥ ដុល្លារ |
| ១៣-លោក **ត តួន** | គណៈកម្មការភូមិអំពិលធ្លង់ | ថវិកាចំនួន | ១.៣៦០ ដុល្លារ |
| ១៤-លោក **ញ៉យ ញឿង** | គណៈកម្មការភូមិអំពិលធ្លង់ | ថវិកាចំនួន | ១.៣២៥ ដុល្លារ |
| ១៥-លោក **រី ហុត** | គណៈកម្មការភូមិព្រៃអា | ថវិកាចំនួន | ១.៣១៥ ដុល្លារ |
| ១៦-លោក **អ៊ាត់ ហ៊ុប** | គណៈកម្មការភូមិដូនមៀវ | ថវិកាចំនួន | ១.៣០០ ដុល្លារ |

**មាត្រា ២ .‐**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៦៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រីប្រចាំការ អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

### សម្រេច

**មាត្រា១.-**

តែងតាំងលោក **សរ សិនិរ៉ា** បច្ចុប្បន្នអនុប្រធាននាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគ នៃគណៈកម្មាធិការវិនិយោគកម្ពុជា ជាប្រធាននាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគ នៃគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២០០ . អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ប្រគល់ភារកិច្ចជូន លោក **ខ៊ាន់ ម៉ិនថា** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ជំនួសឯកឧត្តម **ឈាន លាង** ដែលបានចូលនិវត្តន៍។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** [illegible] អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់មន្ត្រីរាជការឲ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធព័ត៌មានវិទ្យា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានដាក់លោក **ឆាន សារុំ** មុខតំណែងជាអភិបាលស្រុកស្ទឹងហាវ នៃខេត្តព្រះសីហនុ ឋានន្តរស័ក្តិវរមន្ត្រីថ្នាក់លេខ១ ឱ្យចូលនិវត្តន៍ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៥ តទៅ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៣ ... អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ឆាយ សុគន្ធជា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ឱ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២០៧...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងមន្ត្រីពន្ធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី ២០ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២០២អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់សមមូលឋានន្តរសក្តិមន្ត្រីពន្ធនាគារ ជាមួយនឹងឋានន្តរសក្តិមន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិ និងការធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌ មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៤៩៤អនក្រ.តត ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១៤ ស្តីពីការធ្វើសមាហរកម្មមន្ត្រីរាជការបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១** : តែងតាំងមុខតំណែងលោកស្រី **ញ៉ែម អូន** អត្តលេខ ០០៧០ **ជាអគ្គនាយករង** នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ ។

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃ
## មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ស្តីពីការប្រែក្លាយមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា១.-**

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សុខ ផេង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ប្រធាន |
| ២-ឯកឧត្តម | **សេង លឹមនៅ** | ឥស្សរជនមានចំណេះដឹងនិងបទពិសោធន៍ខាងវិទ្យាសាស្ត្រសុខាភិបាល ការងារពិសោធន៍ជាតិនិងអន្តរជាតិ | សមាជិក |
| ៣-លោកជំទាវ | **ឱ វណ្ណឌីន** | តំណាងអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល | សមាជិក |
| ៤-លោកជំទាវ | **ឆាយ សំឡៀង** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-ឯកឧត្តម | **ឯក ធីរដេដ្ឋ** | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក | **ឌឹម ថេង** | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧-លោក | **អ៊ិន សំបូរ** | តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៨-លោក | **ស៊ិន សាន** | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩-លោក | **ទេព ភីឡា** | នាយកមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល | សមាជិកស្វ័យប្រវត្តិ |
| ១០-លោក | **ពិន យសសុជីវី** | តំណាងបុគ្គលិកមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល | សមាជិកស្វ័យប្រវត្តិ។ |

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧/២៨ ខែកុម្ភៈ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២១០ .អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូតជាន់ខ្ពស់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
